# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៧៤

អង្គជំនុំជម្រះសាលាដំបូង បានធ្វើសវនាការតែពីរថ្ងៃប៉ុណ្ណោះក្នុងសប្តាហ៍នេះ ដើម្បីស្តាប់សក្ខីកម្មពាក់ព័ន្ធនឹងសំណុំរឿង០០២ វគ្គ២ ដោយសារតែនៅថ្ងៃពុធ អង្គជំនុំជម្រះតុលាការកំពូលបានបើកកិច្ចប្រជុំ ដើម្បីចេញសេចក្តីសម្រេចចុងក្រោយលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២ វគ្គ១។ សាលដីកាលើបណ្តឹងសាទុក្ខនេះ ត្រូវបានរៀបចំក្នុងរបាយការណ៍ឃ្លាំមើលសវនាការដោយឡែកមួយទៀត។[1] នៅថ្ងៃចន្ទ និងថ្ងៃអង្គារ អង្គជំនុំជម្រះសាលាដំបូង បានស្តាប់សក្ខីកម្មរបស់សាក្សីមួយរូប និងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប។ ទោះបីជាអ្នកទាំងពីរត្រូវបានកោះហៅ ពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទក៏ដោយ ក៏អ្នកទាំងពីរបានផ្តល់សក្ខីកម្មទៅលើប្រធានបទផ្សេងៗជាច្រើនរួមមាន៖ ការបោសសម្អាត និងការរៀបអាពាហ៍ពិពាហ៍ផងដែរ។ អ្នកដែលផ្តល់សក្ខីកម្មដំបូងគេនាសប្តាហ៍នេះ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានអត្តលេខ **2-TCCP-223** ក្រោមវិធានការណ៍ការពារប្រើប្រាស់រហស្សនាម ដោយសារតែការចូលរួមរបស់គាត់ក្នុងកិច្ចស៊ើបសួរលើសំណុំរឿងដែលកំពុងដំណើរ ក៏ប៉ុន្តែ មានឱកាសជាច្រើននៅក្នុងអំឡុងពេលចោទសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ត្រូវបានសុំឲ្យផ្តល់អត្តសញ្ញាណលម្អិតផ្ទាល់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់វិធានការណ៍នេះផងដែរ។ សាក្សីបន្ទាប់ដែលផ្តល់សក្ខីកម្មក្នុងសប្តាហ៍នេះ គឺអ្នកស្រី **ធុច ស៊ីថន** បានផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍ពីទីក្រុងប៉ារីស។ អង្គជំនុំជម្រះ

[1] សូមមើល របាយការណ៍របស់អ្នកឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហមលើសំណុំរឿង០០២ វគ្គ១ ស្តីពីសាលដីកាស្ថាធរលើបណ្តឹងសាទុក្ខ (នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦)។

សាលាដំបូង បានផ្អាកកិច្ចដំណើរការនីតិវិធីសវនាការនៅពេលរសៀល ថ្ងៃអង្គារ និងបន្តកិច្ចដំណើរសវនាការឡើងវិញនៅថ្ងៃចន្ទ សប្តាហ៍ក្រោយជាធម្មតា។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ម៉ាយខល ចេន (Michael Chen), ហាន់ណា ដេយឆ៍ (Hanna Daych), ម៉ាលេនី ហៃដ៍ (Melanie Hyde), ខេតលីន កាហ្វប្រៀ (Caitlin McCaffrie), និន វុទ្ធី, លូវីស រេតវាយលើ (Louise Rettweiler), តាយលីណា និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្តួចផ្តើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់បែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University